របាយការណ៍ស្រាវជ្រាវខ្នាតតូច
ស្តីពី

គណៈកម្មាធិការ
សហប្រតិបត្តិការ
ដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
pour le Cambodge
CCC

# ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ

## និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង

# Labour Migration to Thailand and the Thai-cambodian Border

## Recent Trends in Four Villages of Battambang Province



ស្រាវជ្រាវដោយ: សិក្ខាកាមនៃវគ្គ "អេឌីអាយ" ជំនាន់ទី ១២
សំរបសំរួលដោយអង្គភាពអេឌីអាយ

១២ ធ្នូ ឆ្នាំ២០០៣

# ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ

## និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង

# Labour Migration to Thailand and the Thai-cambodian Border

## Recent Trends in Four Villages of Battambang Province


**ស្រាវជ្រាវដោយ: សិក្ខាកាមនៃវគ្គ "អេឌីអាយ" ជំនាន់ទី ១២**

**សំរបសំរួលដោយអង្គភាពអេឌីអាយ**



**១២ ធ្នូ ឆ្នាំ២០០៣**

# មាតិកា TABLE OF CONTENTS


| | ទំព័រ |
|---|---|
| ១- សេចក្ដីសង្ខេប | ៣ |
| ២- ការពិពណ៌នាអំពីបញ្ហា | ៤ |
| ៣- ទិសដៅនៃការស្រាវជ្រាវ | ៥ |
| ៤- សំណួរគន្លឹះនៃការស្រាវជ្រាវ | ៥ |
| ៥- វិធីសាស្ត្រនៃការស្រាវជ្រាវ | ៧ |
| ៦- លទ្ធផលរកឃើញ និងការវិភាគ | ៨ |
| ៦.១. និន្នាការ | ៨ |
| ៦.២ បរិបទភូមិ | ១៣ |
| ៦.៣ បញ្ហាដែលជួបប្រទះ | ១៥ |
| ៦.៤ ជីវភាពរស់នៅ | ១៨ |
| ៧- សេចក្ដីសន្និដ្ឋាន | ១៩ |
| ៨- អនុសាសន៍ | ២១ |
| ៩- ឧបសម្ព័ន្ធ | ២៣ |
| ៩-១- ផែនទីភូមិ | ២៣ |
| ៩-២- បញ្ជីសំណួរសំភាសន៍អ្នកចាកចេញទៅប្រកបការងារ | ២៤ |
| ៩-៣- បញ្ជីសំណួរសំភាសន៍គ្រួសារអ្នកចាកចេញទៅប្រកបការងារ | ៣៥ |
| ៩-៤- បញ្ជីសំណួរសំភាសន៍ក្រុមថ្នាក់ដឹកនាំភូមិ | ៤៨ |
| ៩-៥- បញ្ជីឈ្មោះសិក្ខាកាម | ៥៤ |

# សេចក្តីសង្ខេប

អង្គភាព អេឌីអាយ ធ្វើការសិក្សានេះដើម្បីវាយតំលៃនូវនិន្នាការនៃការចាកចេញទៅធ្វើការងារនៅប្រទេសថៃ និងតាមព្រំដែនកម្ពុជា-ថៃ របស់ភូមិបួននៅក្នុងខេត្តបាត់ដំបង ។ ដើម្បីសិក្សានូវនិន្នាការនេះបានតំរូវឱ្យពិនិត្យទៅលើបរិបទភូមិដែលជំរុញឱ្យមានការចាកចេញទៅធ្វើការងារនេះ ក្នុងនោះការសិក្សាក៏ពិនិត្យលើបញ្ហាដែលអ្នកចាកចេញទៅ និងគ្រួសាររបស់ពួកគេជួបប្រទះ ព្រមទាំងវិភាគទៅលើជីភាពរស់នៅនៃគ្រួសាររបស់ពួកគេ ដែលជះឥទ្ធិពលមកពីការចេញទៅប្រកបការងារនេះផងដែរ ។

ក្រោយពីសិក្សារួចមកវាលេចឱ្យឃើញយ៉ាងច្បាស់ថា មានគ្រួសារជាច្រើននៅក្នុងភូមិដែលបានសិក្សាសុទ្ធតែបានចាកចេញទៅរកការងារធ្វើ ហើយចំនួនបានកើនឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០០១-២០០៣ ។ ជាការពិតហើយថា តំលៃការងារខ្ពស់ និងឱកាសការងារមាននៅក្នុងប្រទេសថៃ ជាកត្តា "ទាញ" យ៉ាងសំខាន់ក៏ដោយតែកត្តា "ជំរុញ" ពីប្រទេសកម្ពុជាក៏មានតួនាទីសំខាន់ផងដែរ ។ គ្រោះទឹកជំនន់ជាប់ៗគ្នានៅក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ បានជះឥទ្ធិពលធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះ កត្តាទាំងនេះហើយដែលជំរុញឱ្យពួកគាត់ចាកចេញពីផ្ទះសំបែងដើម្បីរកការងារធ្វើតាមកន្លែងផ្សេងទៀត ។ អ្នកចាកចេញទៅប្រកបការងារបានជួបប្រទះបញ្ហាជាច្រើននៅកន្លែងធ្វើការ និងនៅពេលដែលគេត្រឡប់មកផ្ទះវិញ ។

និយាយជារួមអ្នកចាកចេញ ទៅធ្វើការនៅក្រៅមិនអាចយកប្រាក់ដែលខ្លួនរកបានទៅរកស៊ីអ្វីដើម្បីលើកកំពស់ជីវភាពគ្រួសាររបស់គេឡើយ ។ នៅក្នុងបរិបទនិងលក្ខខ័ណ្ឌដែលពួកគេប្រឈមមុខនេះ ហើយថែមទាំងមានឱកាសក្នុងការចាកចេញទៅរកការងារដូច្នោះធ្វើ ការចាកចេញទៅធ្វើការក្រៅនៅតែជាយុទ្ធសាស្ត្រសមស្របក្នុងការចិញ្ចឹមជីវិតគ្រួសាររបស់ពួកគេ ។ ដោយសារតែតំរូវការការងារនៅក្នុងទីផ្សារសេរី នាំឱ្យប្រជាជនកម្ពុជាអាចចល័តក្នុងការស្វែងរកការងារធ្វើ ហើយលើសពីនេះទៀតការបើកច្រកព្រំដែនច្រើនកន្លែង ក៏ជាកត្តាដែលធ្វើការចាកចេញទៅធ្វើការនៅក្នុងប្រទេសថៃ និងតាមព្រំដែនកម្ពុជា-ថៃនៅតែកើនឡើងរហូតដូច្នោះ ។

# ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ

## និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង

### ការពិពណ៌នាអំពីបញ្ហា

ចាប់តាំងពីដើមទសវត្សទី៩០មក ការចេញទៅធ្វើការនៅប្រទេសថៃ និងតំបន់ព្រំដែនថៃបានក្លាយទៅជាប្រភពចំណូលយ៉ាងសំខាន់សំរាប់គ្រួសារនៅខេត្តនៃភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ ក្នុងការចុះធ្វើការស្រាវជ្រាវនៅក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ គំរោងស្តីពីការវិភាគបញ្ហាអភិវឌ្ឍន៍ " អេឌីអាយ "មានការយល់ដឹងកាន់តែច្រើន លើនិន្នាការនេះទៅលើជីវិតរស់នៅរបស់ប្រជាជនសាមញ្ញនៅតាមភូមិ ។ ដើម្បីយល់ឱ្យបានកាន់តែច្បាស់ លើការចាកចេញទៅធ្វើការនៅប្រទេសថៃ និងព្រំដែនថៃ បុព្វហេតុនិងផលវិបាកផ្សេងៗរបស់វា " អេឌីអាយ " បានចុះធ្វើការស្រាវជ្រាវនៅតាមភូមិចំនួនបួននៅក្នុងខេត្តបាត់ដំបង នៅក្នុងខែតុលាឆ្នាំ ២០០៣ ជាមួយនឹងសិក្ខាកាមចំនួន២០នាក់ ។ របាយការណ៍នេះប្រាប់ពីលទ្ធផលដែលបានរកឃើញពីការសិក្សាស្រាវជ្រាវនេះ ។

នៅក្នុងឆ្នាំ ១៩៩៧ វិទ្យាស្ថានស្ថិតិជាតិបានប៉ាន់ប្រមាណថា ចំនួនអ្នកចេញទៅធ្វើការនៅប្រទេសថៃត្រូវជា១២%នៃកំលាំងពលកម្មសរុបនៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប[១] ។ ក្នុងឆ្នាំ ១៩៩៩ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានធ្វើការសិក្សាអំពី ការចាកចេញទៅធ្វើការងារប្រទេសថៃ ក្នុងភូមិចំនួន ១៤ នៅខេត្តបាត់ដំបង[២] ។ ការសិក្សានេះកត់សំគាល់ឱ្យឃើញថាហេតុផលនៃការចាកចេញទៅច្រើនគ្នាទៅប្រទេសថៃ រួមទាំងមានឱកាសការងារធ្វើនៅក្នុងប្រទេសថៃ ព្រមទាំងការផ្តល់ប្រាក់កំរៃច្រើនគួរសម និងការខ្វះការងារធ្វើនៅក្នុងប្រទេសកម្ពុជា ។ ដូចគ្នានេះដែរ ការស្រាវជ្រាវបានរកឃើញថា មានការថយចុះនូវចំនួនអ្នកដែលចាកចេញទៅធ្វើការនៅក្នុងឆ្នាំ១៩៩៨ ដោយសារនៅពេលនោះប្រទេសថៃ មានការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច ។ ការថយចុះនៅពេលនោះ នាំមកនូវបញ្ហាធំៗមួយចំនួនដោយរួមទាំងការមិនបង់ប្រាក់ឈ្នួលអោយ និងការធ្វើទុក្ខបុកម្នេញ ព្រមទាំង ចាប់ខ្លួនពីសំណាក់ប៉ូលីសថៃ ។ ឥឡូវនេះ បួនឆ្នាំកន្លង ទៅហើយ ទោះបីជាអ្នកចាកចេញទៅធ្វើការ និងគ្រួសាររបស់គេជួប

---

[1] *Socio-Econmic Survey of Cambodia 1996 (*Phnom Penh: National Institute of Statistics, 1997), Vol. 2.

[2] ចាន់ សុផល និង សូ សុវណ្ណារិទ្ធិ: *Cambodian Labor Migration to Thailand: A Preliminary Assessment*, Working Paper 11 (Phnom Penh: CDRI, June 1999).

ប្រទះបញ្ហាច្រើនក៏ដោយ ក៏ការចេញទៅធ្វើការនៅប្រទេសថៃ នៅតែមានជាបន្ត ហើយជាមុខរបរចិញ្ចឹមជីវិតមួយយ៉ាងសំខាន់សំរាប់គ្រួសារ ជាច្រើននៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។

ការស្រាវជ្រាវរបស់គំរោង ADI នៅពេលនេះ មានបំណងសិក្សាវាយតំលៃនិន្នាការថ្មីៗនេះ នៃការចេញទៅរកការងារធ្វើនៅប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃ ពីភូមិចំនួន៤នៅក្នុងខេត្តបាត់ដំបង ។ ការស្រាវជ្រាវនេះក៏ពិនិត្យមើលទៅលើផលវិបាកពីការធ្វើបាតុកម្មប្រឆាំងនឹងថៃកាលពីខែមករា ឆ្នាំ២០០៣ នៅទីក្រុងភ្នំពេញ ។ ការស្រាវជ្រាវក៏មានបំណងពិនិត្យមើលផងដែរទៅលើបរិបទ ដែលបណ្តាលអោយមានចំណាកស្រុក កំណត់រកមើលបញ្ហាដែលកើតចេញពីការធ្វើចំណាកស្រុកនៃអ្នកដែលចេញទៅ និងគ្រួសាររបស់គេដែលនៅឯផ្ទះ ហើយពិនិត្យមើលការប្រែប្រួលជីវភាពរបស់គ្រួសារដែលបានធ្វើចំណាកស្រុក ។

## ទិសដៅនៃការស្រាវជ្រាវ

១- ដើម្បីប៉ាន់ប្រមាណពីនិន្នាការនៃការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ នៅក្នុងភូមិចំនួន៤ នៃឃុំមួយក្នុងខេត្តបាត់ដំបង ។

២- ដើម្បីស្វែងយល់ពីស្ថានភាពនៅក្នុងភូមិដែលបង្កឱ្យមានការចេញទៅប្រកបការងារ នៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ ។

៣- ដើម្បីកំណត់នូវបញ្ហានានា ដែលអ្នកចេញទៅប្រកបការងារ និងគ្រួសាររបស់គេជួបប្រទះ បណ្តាលមកពីការចេញទៅប្រកបការងារនៅខាងក្រៅ ។

៤- ដើម្បីពិនិត្យមើលថាតើការចេញទៅប្រកបការងាររបស់ពួកគេ ជះឥទ្ធិពលដូចម្តេចខ្លះមកលើជីវភាពរស់នៅរបស់គ្រួសារគេ?

## សំណួរគន្លឹះនៃការស្រាវជ្រាវ

### និន្នាការ

១- តើនៅពេលថ្មីៗនេះ ( ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែកញ្ញា ឆ្នាំ ២០០៣) ការចេញទៅប្រកប

ការងារនៅប្រទេសថៃ និង ព្រំដែនកម្ពុជា-ថៃ មានការកើនឡើង ឬថយចុះ ឬនៅដដែល ? នៅអំឡុងពេលនេះ តើមានព្រឹត្តិការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយ សំខាន់ៗអ្វីខ្លះ ដែលជះឥទ្ធិពលដល់ការចាកចេញទៅប្រកបការងារនេះ?

២- តើទីកន្លែងដែលអ្នកចេញទៅប្រកបការងារនៅប្រទេសថៃ ភាគច្រើនគឺចូលជ្រៅទៅក្នុងប្រទេសថៃ (នៅបាងកក ឬនៅកន្លែងផ្សេងទៀត នៅក្នុងប្រទេសថៃ) ឬមួយក៏ទៅរាក់ៗតាមព្រំដែន (នៅតាមព្រំដែនកម្ពុជា-ថៃ)?តើការស្នាក់នៅដើម្បីធ្វើការរបស់ពួកគេភាគច្រើនមានរយៈពេលវែងឬខ្លី?

៣- តើអ្នកចាកចេញទៅប្រកបការងារភាគច្រើន ជាបុរស ឬស្ត្រី? នៅលីវ ឬរៀបការហើយ? ក្មេង ឬចាស់? ជាអ្នកមានឬក្រ?

**បរិបទភូមិ**

១- តើហេតុអ្វីបានជាសមាជិកគ្រួសារ ចាកចេញទៅប្រកបការងារនៅប្រទេសថៃ និងតាមព្រំដែនកម្ពុជា-ថៃ?

២- តើមូលហេតុទាំងនោះជាបញ្ហាផ្ទាល់ខ្លួននៅក្នុងគ្រួសារគេ (ដូចជាជំងឺ ឬពុំមានដីធ្វើស្រែ) ឬជាបញ្ហាគ្រោះធម្មជាតិ (ដូចជាគ្រោះទឹកជំនន់) ឬក៏បណ្តាលមកពីគ្មានឱកាសការងារនៅក្នុងភូមិ?

៣- តើស្ថានភាពក្នុងតំបន់ដែលជំរុញឱ្យមានការចេញទៅប្រកបការងារនៅខាងក្រៅ ទំនងជាមានការប្រែប្រួលឬទេ នៅអំឡុងពេលដ៏ខ្លីខាងមុខនេះ?

**បញ្ហាដែលជួបប្រទះ**

១- តើអ្នកចាកចេញទៅប្រកបការងារបានជួបប្រទះនូវបញ្ហាអ្វីខ្លះ ក្នុងការស្វែងរកការងារធ្វើនៅប្រទេសថៃ និងតាមព្រំដែនកម្ពុជា-ថៃ? តើពួកគេដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា?

២- តើអ្នកចាកចេញទៅប្រកបការងារនៅប្រទេសថៃ និងតាមព្រំដែនជួបប្រទះនូវបញ្ហាអ្វីខ្លះ នៅពេលពួកគេត្រឡប់មកផ្ទះវិញ? តើពួកគេដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា?

៣- តើគ្រួសាររបស់គេដែលនៅផ្ទះជួបប្រទះនូវបញ្ហាអ្វីខ្លះ នៅពេលមានសមាជិកគ្រួសារគេចេញទៅប្រកបការងារ? តើពួកគេដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា?

**ជីវភាពរស់នៅ**

១- តើជីវភាពរស់នៅគ្រួសាររបស់គេមានការកើនឡើង ឬថយចុះ ឬក៏នៅដដែល ក្រោយពីគេចេញទៅប្រកបការងារ?

២- តើអ្នកដែលចេញទៅប្រកបការងារបានប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេសំរាប់ ទិញរបស់របរដូចជាដីធ្លី ឬចាប់ផ្តើមមុខរបរថ្មី ដូចជាជំនួញខ្នាតតូចដែរឬទេ?

៣- តើការចាកចេញទៅធ្វើការនៅប្រទេសថៃ ឬព្រំដែនកម្ពុជា-ថៃ ជាមុខរបរអចិន្ត្រៃយ៍សំរាប់គ្រួសាររបស់អ្នកឬយ៉ាងណា?

## វិធីសាស្ត្រនៅក្នុងការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយសិក្ខាកាម ចំនួន២០នាក់ នៃវគ្គសិក្សា ADI ជំនាន់ទី១២ដោយមានការសំរបសំរួលពីក្រុម ADI ចំនួន៥នាក់ ។ សរុបទាំងអស់ទៅមានស្ត្រី ១០នាក់ បុរស១៥នាក់ចូលរួមនៅក្នុងការស្រាវជ្រាវនេះ ។ ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២-៣ ខែតុលាឆ្នាំ២០០៣ នៅក្នុងភូមិចំនួនបួននៅក្នុងឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង។ ភូមិទាំងបួនដែលត្រូវបានស្រាវជ្រាវនោះគឺ ភូមិអង់ គោកក្ដួច ប៉ោយយ៉ុង និងទំពូង (សូមមើលផែនទី) ។ អ្នកស្រាវជ្រាវត្រូវបានបែងចែកជាបួនក្រុមតូចៗ ដោយក្រុមនិមួយៗទទួលខុសត្រូវនៅក្នុងការប្រមូលពតិមាននៅក្នុងភូមិនិមួយៗនៅក្នុងចំណោមភូមិទាំងបួន ។

វិធីសាស្ត្រស្រាវជ្រាវសំខាន់ពីរត្រូវបានយកមកប្រើរួមមានៈ ការសំភាសន៍ក្រុម ជាមួយនឹងអ្នកដឹកនាំសំខាន់ៗក្នុងភូមិ បញ្ជីសំណួរស្រាវជ្រាវជាបុគ្គលជាមួយអ្នកវិលត្រឡប់មកពីធ្វើការវិញ និងជាមួយនឹងគ្រួសារនៃអ្នកដែលមិនទាន់ត្រឡប់មកវិញ ។ ការសំភាសន៍ជាក្រុមបានធ្វើនៅក្នុងភូមិទាំងបួន រួមមានៈ ប្រធានភូមិ សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មេដឹកនាំស្ត្រី អ្នកដែលវិលត្រឡប់មកពីធ្វើការវិញ និងនគរបាលនៅតាមមូលដ្ឋាន ។ ដូចគ្នានេះដែរ ការសំភាសន៍បុគ្គលនៅក្នុងភូមិបួននោះ ត្រូវបានធ្វើឡើងតាមការជ្រើសរើសសំណាក តាមវិធីសាស្ត្រ Purposive ជាមួយនឹងអ្នកដែលវិលត្រឡប់មកវិញ និងជាមួយសមាជិកនៃគ្រួសារនៃអ្នកដែល កំពុងចាកចេញទៅហើយដែលមិនទាន់ត្រឡប់មកវិញ ។ ការសំភាសន៍ជាលក្ខណៈបុគ្គលទាំងពីរប្រភេទនេះ មិនត្រូវបានធ្វើឱ្យជាន់គ្នានោះទេ ។

នៅក្នុងភូមិអង់ គោកក្តួច និងប៉ោយយ៉ុង អ្នកវិលត្រឡប់មកវិញ ចំនួន ១៥នាក់ និងគ្រួសារចំនួន១៥នាក់ របស់អ្នកដែលចាកចេញទៅមិនទាន់ត្រឡប់មកវិញត្រូវបានសំភាសន៍នៅក្នុងភូមិនិមួយៗ ។ រីឯនៅភូមិទំពូង អ្នកចេញទៅធ្វើការចំនួន ១៦នាក់ និងគ្រួសាររបស់អ្នកមិនទាន់ត្រឡប់មកវិញចំនួន ១៣គ្រួសារ ត្រូវបានសំភាសន៍ ។ ដូច្នេះសរុបទាំងបួនភូមិ អ្នកចេញទៅចំនួន ៦១នាក់ និងគ្រួសាររបស់អ្នកដែលមិនទាន់ត្រឡប់មកវិញចំនួន ៥៨គ្រួសារ ត្រូវបានគេសំភាសន៍ ។ ដោយសារភាពដូចគ្នាភាគច្រើននៃបញ្ជីសំណួរសំភាសន៍ ធ្វើអោយក្រុមស្រាវជ្រាវអាចបញ្ចូលចំលើយទាំងអស់រួមគ្នាដែលមានចំនួន ១១៩ នាក់ ។

## លទ្ធផលរកឃើញ និងការវិភាគ

### និន្នាការ

ការពិភាក្សាជាក្រុមបញ្ជាក់ច្បាស់ថា ចំនួនដ៏ច្រើននៃគ្រួសារដែលរស់នៅក្នុងភូមិ មានសមាជិកបានចេញទៅប្រទេសថៃ ឬតំបន់ព្រំដែនកម្ពុជា-ថៃ ដើម្បីស្វែងរកការងារធ្វើ ។ ទីកន្លែងធ្វើការងាររបស់ពួកគេគឺ នៅតាមព្រំដែន ហើយរយៈពេលនៃការចាកចេញគឺមានពី ១ខែ ទៅ២ខែ ។ ទោះជាយ៉ាងណាក្តី ការនាំគ្នាចេញទៅរកការងារធ្វើដើម្បីជាមធ្យោបាយចិញ្ចឹមជីវិតគឺមានច្រើនគួរអោយភ្ញាក់ផ្អើល ។ ក្រុមពិភាក្សាបានប៉ាន់ប្រមាណថា ប្រហែល ៦៨%នៃគ្រួសារចំនួន ២៩៥ នៅក្នុងភូមិអង់ មានសមាជិកដែល

បានចេញទៅធ្វើការនៅក្នុងប្រទេសថៃ ឬតំបន់ព្រំដែនកម្ពុជា-ថៃ ។ ដូចគ្នានេះដែរ ក្រុមពិភាក្សាបានប៉ាន់ប្រមាណថា ៧៨% នៃគ្រួសារចំនួន ៥១៦ នៅក្នុងភូមិគោកក្លូច មានសមាជិកចេញទៅធ្វើការ ។ រីឯក្រុមពិភាក្សានៅក្នុងភូមិបាំងយង់ បានប៉ាន់ប្រមាណឱ្យឃើញថា ៥០% នៃគ្រួសារ ចំនួន ៥១៥ មានសមាជិកចេញទៅធ្វើការ ។ នៅក្នុងពេលជាមួយគ្នានោះ នៅក្នុងភូមិទំពូង ក្រុមពិភាក្សាបានប៉ាន់ប្រមាណថា គ្រួសារទាំង ៣៨៨ នៅក្នុងភូមិមានសមាជិកចេញទៅធ្វើការ ។ ក្រុមពិភាក្សានៅក្នុងភូមិទាំងបួនបានរាយការណ៍ថាអ្នកចេញទៅធ្វើការមានទាំងបុរសទាំងនារី ហើយថា មានការកើនឡើងយ៉ាងគំហ៊ុកនៃចំនួនអ្នកចេញទៅធ្វើការនៅក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ។

សំណាកសរុបដែលជ្រើសរើសសំរាប់សំភាសន៏ជាលក្ខណៈបុគ្គលមាន ១១៩ នាក់ ក្នុងនោះមាន ៦១នាក់ ជាអ្នកបានត្រឡប់មកវិញ ។ ក្នុងចំណោមអ្នកដែលបានត្រឡប់មកវិញនេះ មាន ៤៨% ជាស្ត្រី និង ៥២% ជាបុរស ។ ភាគច្រើននៃពួកគេមានអាយុពី ១៨ ទៅ ៣០ ឆ្នាំ (៤៤%) និងអាយុពី ៣១ ទៅ ៤៥ ឆ្នាំមាន ៤១%។ អ្នកខ្លះទៀតមានអាយុពី ៤៦ ទៅ ៦១ ឆ្នាំ មានចំនួន ១១% និង អាយុលើសពី ៦០ឆ្នាំ មានចំនួន ២% អ្នកមានអាយុក្រោម ១៨ ឆ្នាំ មានចំនួន ២% ។ ជាងពាក់កណ្ដាលនៃអ្នកចាកចេញទៅរកការងារធ្វើគឺ បានរៀបការហើយ (៥៧%) អ្នកនៅលីវមានចំនួន ២១% និង មេម៉ាយនិងពោះម៉ាយមានចំនួន (២១%)[៣] ។ អ្នកចាកចេញទៅធ្វើការងារដែលមិនបានរៀនសូត្រអ្វីទាំងអស់មានចំនួន ៣៤% អ្នកដែលបានរៀនសូត្រពីថ្នាក់ទី១ ដល់ ថ្នាក់ទី៦ មានចំនួន ៥៤% ចំណែកឯ ៨% ទៀតបានរៀនដល់ថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ហើយមានតែ ៥%ទេ ដែលមានរៀនសូត្រដល់ថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ។ ទំហំសមាជិកក្នុងគ្រួសារជាមធ្យមគឺ ៥.៩ នាក់ តែជាមធ្យមចំនួនអ្នកដែលអាចរកប្រាក់សំរាប់ផ្គត់ផ្គង់គ្រួសារគឺមានតែ ២.៧ នាក់ប៉ុណ្ណោះ ។

ក្រៅពីការសំភាសន៏ជាមួយអ្នកចាកចេញទៅចំនួន ៦១នាក់ យើងក៏បានសំភាសន៏ជាមួយគ្រួសារដែលមានសមាជិកគេមិនទាន់ត្រឡប់មកវិញចំនួន ៥៨គ្រួសារផងដែរ ។ ពួកគាត់ត្រូវបានសួរនូវសំណួរស្ដីពីបទពិសោធន៏សំខាន់ៗរបស់សមាជិកគ្រួសារដែលបានចាកចេញទៅ ។ តាមការពិនិត្យលើចំនួននៃការចេញដំណើរទៅតាមឆ្នាំ បង្ហាញនូវលទ្ធផលគួរអោយកត់សំគាល់ (តារាង ទី១) ។ ដំបូងគឺគេមើលឃើញ

[៣] ភាគរយជាទិច្ចជាកាលមិនអាចគំឡើងដល់ ១០០ បានទេ ។

ច្បាស់ភ្លាមថា ភាគច្រើននៃអ្នកដែលចាកចេញទៅនោះ (៧៦%)ក្នុងចំណោម អ្នកដែលបានសំភាសន៍បានចេញទៅលើសពីមួយដង ។ តាមពិត គិតជាមធ្យមគេម្នាក់ៗចេញទៅ គឺ២,៨ ដង ។ នៅក្នុងពេលជាមួយគ្នានោះ ចំនួននៃការចាកចេញទៅបានកើនលើសទ្វេដងបើប្រៀបធៀបពីចន្លោះ ពេលមួយទៅចន្លោះពេលមួយ ។ អ្វីដែលធ្វើអោយមានការភ្ញាក់ផ្អើលច្រើនជាងគេគឺថា ចំនួននៃការចេញ ដំណើរនៅក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ គឺពីឆ្នាំ ២០០១ ទៅ ២០០៣ ត្រូវជា៦៦% នៃចំនួននៃការចេញដំណើរសរុបរបស់អ្នកដែលបានសំភាសន៍ ។ ទោះបីជាមានការប្រែប្រួលដែលអាចមានពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំក្តី តែការចាកចេញទៅរកការងារធ្វើ មានការកើនឡើងជាលំដាប់ ។

ជាងពាក់កណ្តាល ៥៤%នៃចំនួនអ្នកចាកចេញទៅធ្វើការងារសរុប ១១៩នាក់ បានធ្វើដំណើរម្តងៗមានរយៈពេលពី ១ខែ ទៅ ៦ខែ ។ ចំណែកឯ ១២% ទៀតនៃការធ្វើដំណើរទៀតគឺមានរយៈពេលពី ៦ខែ ទៅ ១ឆ្នាំ ។ រីឯដំណើរ ១៥% ទៀតគឺមានរយៈពេលពី ១ឆ្នាំ ទៅ ៣ឆ្នាំ ហើយមានតែដំណើរ ២%ទេ ដែលមានរយៈពេលលើសពី ៣ឆ្នាំ ។ ក្នុងនោះក៏មាន ១៦%នៃដំណើរដែរ ដែលមានរយៈពេល តិចជាង ១ខែ ។ មួយភាគបីនៃដំណើរដែលគេចាកចេញទៅបានយកសមាជិកគ្រួសារទៅជាមួយរួមមានកូន និងចៅផងដែរ ។

| តារាងទី១. ការធ្វើដំណើរចេញរបស់អ្នកចំណាកស្រុក ខែតុលា ឆ្នាំ ២០០៣ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ដំណើរ ទី១ | ដំណើរ ទី២ | ដំណើរ ទី៣ | ដំណើរ ទី៤ | ដំណើរ ទី៥ | ដំណើរ ទី៦ | ដំណើរ ទី៧ | សរុប |
| មុន ៩០ | ៣ | - | - | - | - | - | - | ៣ |
| ៩០-៩៤ | ៥ | ២ | - | - | - | - | - | ៧ |
| ៩៥-៩៧ | ១៨ | ៥ | ៣ | ១ | ១ | ១ | ១ | ៣០ |
| ៩៨-០០ | ៣១ | ២០ | ១០ | ៨ | ២ | ១ | - | ៧២ |
| ០១-០៣ | ៦១ | ៦៣ | ៤០ | ១៩ | ១៦ | ១១ | ៤ | ២១៤ |
| សរុប* | ១១៨ | ៩០ | ៥៣ | ២៨ | ១៩ | ១៣ | ៥ | ៣២៦ |
| n=១១៩ | | | | | | | | |
| *ចំណាំៈ មានអ្នកឆ្លើយម្នាក់មិនចាំឆ្នាំដែលគាត់ធ្វើដំណើរ | | | | | | | | |

ការចេញទៅធ្វើការរបស់អ្នកភូមិដែលត្រូវបានសិក្សានោះគឺ មានទាំងទៅឆ្ងាយនិងទៅជិត ។ អ្នកទៅឆ្ងាយគឺចូលជ្រៅ ទៅក្នុងប្រទេសថៃរហូតដល់ក្រុងបាងកក និងទីក្រុងធំៗដទៃទៀត ។ អ្នកដែលទៅជិតគឺធ្វើការនៅតាមស្រែចំការតាមបណ្តោយព្រំដែនកម្ពុជា-ថៃ[4] ។ ក្នុងចំណោមអ្នកដែលបានសំភាសន៍គឺ មាន ៥២% បានចូលជ្រៅទៅក្នុងប្រទេសថៃ និង៤៨%ទៅជិតៗព្រំដែន (សូមមើលតារាងលេខ ២) ។ នៅពេលជាមួយគ្នានោះដែរ មាន៤០% គឺចេញទៅធ្វើការនៅតាមព្រំដែនកម្ពុជា-ថៃ ហើយ៦០% ទៀតធ្វើដំណើរទៅធ្វើការនៅតាមព្រំដែនក្នុងប្រទេសកម្ពុជា ។ ប្រហែលដូចដែលគេគិតមែន អ្នកដែលចេញទៅឆ្ងាយធ្វើដំណើរតិចដង (២,៤ដង) ជាងអ្នកធ្វើដំណើរជិត (៣,២ដង) ។

| តារាងទី២. ការធ្វើដំណើរទៅកាន់គោលដៅរបស់អ្នកចេញទៅធ្វើការ ខែតុលា ឆ្នាំ ២០០៣ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| កន្លែងគោលដៅ | ដំណើរ ទី១ | ដំណើរ ទី២ | ដំណើរ ទី៣ | ដំណើរ ទី៤ | ដំណើរ ទី៥ | ដំណើរ ទី៦ | ដំណើរ ទី៧ | សរុប |
| ទៅឆ្ងាយ | ៧៣ | ៤៦ | ២៦ | ១៥ | ៦ | ៤ | ៣ | ១៧៣ |
| ទៅជិត (ក្នុង ទឹកដីថៃ) | ២៤ | ១៨ | ៨ | ៧ | ៤ | ២ | ១ | ៦៤ |
| ទៅជិត (ក្នុង ទឹកដីខ្មែរ) | ២៦ | ២៤ | ២០ | ៩ | ៧ | ៦ | ៤ | ៩៦ |
| សរុប | ១២៣ | ៨៨ | ៥៤ | ៣១ | ១៧ | ១២ | ៨ | ៣៣៣ |
| n= ១១៩ | | | | | | | | |
| ចំណាំ: មួយចំនួននិយាយថាពេលចេញទៅម្តងៗ គេទៅច្រើនកន្លែង | | | | | | | | |

មានដំណើរចំនួន ៤៥% នៃដំណើរសរុប ១១៩នាក់ បានទៅដោយមានការនាំផ្លូវពីមេខ្យល់ដើម្បីទៅធ្វើការងារក្នុងប្រទេសថៃ និងតាមព្រំដែន ។ អ្នកចាកចេញច្រើនតែពឹងផ្អែកលើមេខ្យល់តែដំណើរដំបូងរបស់ពួកគេ ។ ការបង់ថ្លៃឱ្យមេខ្យល់គឺពី ២០០០ ទៅ ៣០០០ បាត (ប្រហែលជាពី ៥០-៧៥ ដុល្លាអាមេរិច) ។ គួរឱ្យកត់សំគាល់មាន ៨២% នៃអ្នកចាកចេញទៅធ្វើការងារ បានខ្ចីលុយគេដើម្បីធ្វើសោហ៊ុយក្នុងការធ្វើដំណើរ ។ ភាគច្រើនគឺពួកគាត់ខ្ចីច្រើនជាង ២០០០ បាត ហើយច្រើនតែខ្ចីពីអ្នក

[4] See Chan & So, *Cambodian Labour Migration to Thailand, 5.*

រកស៊ីចងការលុយដែលមានការប្រាក់ខ្ពស់ ។ យើងរកឃើញថា មាន ២៤%នៃអ្នកចាកចេញនោះមិនទាន់អាចសងបំណុលគេនៅឡើយទេ ។

ប្រភេទការងារដែលអ្នកចេញទៅធ្វើការ ដោយចូលជ្រៅទៅក្នុងប្រទេសថៃ ខុសប្លែកពីការងារដែលមាននៅតាមព្រំដែនកម្ពុជា-ថៃ(សូមមើលតារាងទី៣) ។ អ្នកដែលចេញទៅធ្វើការនៅកន្លែងឆ្ងាយច្រើនធ្វើការផ្នែកសំណង់ ការងារដឹកជញ្ជូន ការងារក្នុងផ្ទះ ការងារតាមភោជនីយដ្ឋាន និងការជួញដូរតូចតាច ។ ចំណែកឯអ្នកដែលចេញទៅធ្វើការនៅតំបន់ជិតៗ គឺច្រើនធ្វើការនៅតាមស្រែចំការ ដូចជា រានដីបេះពោត សណ្តែក និងផ្លែឈើ ច្រូតស្រូវ និងដាំអំពៅ ។

| តារាងទី៣. ប្រភេទនៃការងាររបស់អ្នកដែលចេញទៅឆ្ងាយនិងជិត ខែតុលា ឆ្នាំ ២០០៣ | | | |
|---|---|---|---|
| ប្រភេទនៃការងារ | ទៅឆ្ងាយ | ទៅជិត | សរុប |
| កម្មករសំណង់ | ៣៤ | ២ | ៣៦ |
| កម្មករដឹកជញ្ជូន | ១៦ | ៣ | ១៩ |
| អ្នកស៊ីឈ្នួលតាមផ្ទះ | ១២ | ២ | ១៤ |
| អ្នករត់តុ | ៩ | ២ | ១១ |
| ជួញដូរតូចតាច (សាច់ជ្រូក ត្រី និងផ្លែឈើ) | ៩ | ១ | ១០ |
| ដាំអំពៅ | ៤ | ៩ | ១៣ |
| ស្ទូងស្រូវ | ៤ | ៨ | ១២ |
| រានស្រែចំការ | ៣ | ២៨ | ៣១ |
| ច្រូតស្រូវ | ៣ | ៩ | ១២ |
| កម្មកររោងចក្រ | ៣ | ០ | ៣ |
| កម្មករនេសាទ | ៣ | ០ | ៣ |
| ដកដំឡូងមី | ២ | ៥ | ៧ |
| ការងារជាងឈើ | ២ | ២ | ៤ |
| អ្នកបោសសំអាតអោយក្រុមហ៊ុន | ២ | ០ | ២ |

| | | | |
|---|---|---|---|
| ប្រមូលផលសណ្តែក/ផ្លែឈើ | ១ | ១០ | ១១ |
| ដាំបង្គោលខ្សែភ្លើង | ១ | 0 | ១ |
| បេះសណ្តែកសៀង | ១ | 0 | ១ |
| សុំទាន | ១ | 0 | ១ |
| ចិញ្ចឹមមាន់ ត្រី | ១ | 0 | ១ |
| ប្រមូលផលពោត | 0 | ២៤ | ២៤ |
| n = 119* | | | |
| ចំណាំៈ អ្នកចេញទៅខ្លះធ្វើការច្រើនមុខនៅពេលចេញទៅម្តងៗ ឬ នៅក្នុងដំណើរខុសៗគ្នា ។ | | | |

ក្នុងចំណោម ១១៩ នៃការធ្វើដំណើររបស់ពួកគេបានទទួលប្រាក់សំរាប់ការស្នាក់នៅ ពោលគឺ ៥៨% បើប្រៀបធៀបជាមួយនឹងការទទួលប្រាក់សំរាប់ម្ហូបអាហារវិញគឺមានតែ ១៥%នៃដំណើរប៉ុណ្ណោះ ។ ចំពោះប្រាក់កំរៃវិញពីម្នាក់ទៅម្នាក់ទទួលបានខុសៗគ្នា មួយភាគបីនៃអ្នកចាកចេញទៅទទួលបានប្រាក់កំរៃលើសពី ៣000បាតក្នុង១ខែៗ ។ ហើយមួយភាគបីនៃអ្នកចាកចេញបានទទួលប្រាក់កំរៃពី ២00១ ទៅ ៣000 បាតក្នុង១ខែ ។ ចំណែកឯមួយភាគបីផ្សេងទៀតទទួលបានប្រាក់កំរៃតែ ២000 ឬតិចជាងនេះផងក្នុង ១ខែ ។ ដូចដែលបានរៀបរាប់ខាងលើ នៅពេលគេចាកចេញទៅម្តងៗ គេច្រើនតែខ្ចីលុយគេដើម្បីបង់ឱ្យមេខ្យល់ ក្នុងការនាំផ្លូវពួកគេចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ ហើយលើសពីនេះទៅទៀតការងារដែលពួកគេធ្វើ នោះច្រើនតែការងារដែលមានតាមរដូវកាល ។

## <u>**បរិបទភូមិ**</u>

ហេតុផលដែលគេលើកឡើងចំពោះការចេញទៅធ្វើការនៅប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃ បង្ហាញពីកត្តារួមផ្សំគ្នាពីរគឺ "កត្តាជំរុញ" និង "កត្តាទាញ" ទោះបីជាកត្តាជំរុញត្រូវបានគេលើកឡើងញឹកញាប់ក៏ដោយ (តារាងទី ៤)។ ៦១%នៃអ្នក ដែលបានឆ្លើយបាននិយាយថា នៅប្រទេសថៃមានការងារធ្វើ ។ ៧៦% បាននិយាយថា មិនមានការងារគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា ។ ៦១% និយាយថា គេមិនមានដីធ្វើស្រែ ។ ៥១%និយាយថា គេមិនមានទុនប្រកបរបររកស៊ី ។ អ្នកឆ្លើយខ្លះបានលើកឡើង ពីបំណុលដែល

បណ្តាលមកពីការមើលជំងឺ (២៧%) បំណុលដោយសារតែធ្វើស្រែចំការ (២១%) និងកង្វះស្បៀង (១៦%) ។

| តារាងទី៤: ហេតុផលដែលធ្វើអោយគេចាកចេញទៅទៅធ្វើការនៅប្រទេសថៃ និង តំបន់ព្រំដែនកម្ពុជាថៃ តុលា ឆ្នាំ ២០០៣ | |
|---|---|
| ហេតុផលនៃការចាកចេញ | |
| មិនសូវមានការងារធ្វើក្នុងប្រទេសកម្ពុជា | ៩០ |
| នៅថៃមានការងារធ្វើ | ៧២ |
| គ្មានដីធ្វើស្រែ | ៧២ |
| មិនមានដើមទុនសំរាប់ប្រកបមុខរបរ | ៦១ |
| មើលជំងឺជំពាក់គេ | ៣២ |
| ធ្វើស្រែជំពាក់គេ | ២៥ |
| ខ្វះខាតស្បៀង | ១៩ |
| ធ្វើស្រែមិនសូវបានផល | ៦ |
| ខ្វះកំលាំងអូសទាញ | ១ |
| n = 119 | |

ការពិភាក្សាជាក្រុមបញ្ជាក់កាន់តែច្បាស់លើបញ្ហាទាំងនេះ ។ នៅក្នុងភូមិអង់ អ្នកចូលរួមពិភាក្សាបាននិយាយថាទឹកជំនន់នៅក្នុងរយៈពេលបីឆ្នាំកន្លងមកធ្វើអោយស្រូវរបស់គេមិនសូវបានផល ហើយគេត្រូវជាប់បំណុលដោយសាររឿងធ្វើស្រែមិនសូវបានផលទៀតផង ។ នេះជាហេតុជំរុញអោយគ្រួសារខ្លះលក់ដីហើយទៅធ្វើការនៅកន្លែងផ្សេង ។ ការមិនសូវមានឱកាសការងារធ្វើនៅក្បែរៗភូមិនិងកំនើននៃសមាជិកគ្រួសារ ក៏ជាកត្តាសំខាន់ផងដែរ ។ នៅក្នុងភូមិគោកក្តួច អ្នកចូលរួមពិភាក្សាបាននិយាយ ពីស្ថានភាពប្រហាក់ប្រហែលគ្នានេះគឺ ទិន្នផលស្រូវទាប ភាពគ្មានដីធ្លី និងកង្វះដើមទុន ដើម្បីយកទៅប្រកបមុខរបរ ធ្វើអោយអ្នកភូមិចេញទៅធ្វើការនៅប្រទេសថៃនិងតំបន់ព្រំដែនថៃ ។ នៅក្នុងភូមិទំពូង សមាជិកក្រុមពិភាក្សាបានលើកឡើងពីការមិនសូវមានការងារធ្វើនៅតំបន់ក្បែរខាង ដែលជាហេតុចំបងធ្វើអោយគេចេញទៅរក

ការងារធ្វើនៅទីឆ្ងាយ ។ នៅក្នុងភូមិប៉ោយយង់ គេបានលើកឡើងពីទឹកជំនន់ ដែលចេះតែកើតមាន ដែលជាកត្តាសំខាន់ធ្វើអោយទិន្នផលស្រូវទាប កំណើននៃបំណុលនិងការលក់ដីធ្លី ។ ដោយមិនអាចរកប្រភពចំណូលផ្សេងទៀតនៅក្បែរភូមិបាន អ្នកភូមិត្រូវចេញទៅរកការងារធ្វើនៅកន្លែងផ្សេង ។

ការខ្វះខាតដីស្រែសំរាប់បង្កបង្កើនផលគឺជាបញ្ហាដែលគួរឱ្យកត់សំគាល់ផងដែរ នៅក្នុងចំណោមអ្នកដែលបានសំភាសន៍ទាំង ១១៩នាក់ ។ ជិត ៦០% នៃអ្នកចាកចេញទៅដែលបានសំភាសន៍និយាយថាគ្រួសារគាត់មិនមានដីស្រែទេ ។ ចំណែក ៤០% ទៀតបានលក់ដីស្រែរបស់គេ ។ ហេតុផលទាំងឡាយដែលធ្វើឱ្យពួកគេលក់ដីរួមមាន: ជំងឺ ស្លាប់ បំណុល ខ្វះស្បៀងអាហារ និងប្រាក់កាស ។ អ្វីដែលគួរឱ្យចំឡែកជាងនេះទៀតគឺមាន ២៣% នៃអ្នកចាកចេញ មានដីស្រែ តែបែជាមិនធ្វើស្រែទៅវិញ ។ ការគ្មានដីធ្លី និងទិន្នផលស្រូវទាបធ្វើឱ្យកំនើននៃការចាកចេញទៅធ្វើការងារក្រៅ ។

## <u>បញ្ហាដែលបានជួបប្រទះ</u>

មានសំណួរមួយសួរថា តើអ្នកជួបប្រទះនូវបញ្ហាអ្វីខ្លះ នៅពេលដែលអ្នកចេញទៅប្រកបការងារនៅប្រទេសថៃ និង តំបន់ព្រំដែនកម្ពុជា-ថៃ (តារាងទី ៥) ។ ជាការចំឡែកមួយដែលថា មាន ៣៨% ត្រូវបានប៉ូលីសចាប់ ។ ភស្តុតាងបង្ហាញថា ការចាប់នេះគឺមានរយះពេលខ្លីទេ ហើយគេដោះលែងវិញ ក្រោយពីបានបង់លុយខ្លះដល់ប៉ូលីស ។ ទោះយ៉ាងណាក្តី មាន១១% បាននិយាយថាបានទទួលការធ្វើទារុណកម្ម ។ អ្នកខ្លះនិយាយថា គេមិនបានទទួលប្រាក់កំរៃគ្រប់ចំនួនទេ (១៨%) ហើយឈឺដោយសារធ្វើការលើសកំលាំង (៧%) ។ គួរកត់ចំណាំថា ៣៦%នៃអ្នកឆ្លើយបាននិយាយថាគេមិនមានជួបនឹងបញ្ហាអ្វីទេ ។

| តារាងទី៥. បញ្ហាដែលអ្នកចេញទៅធ្វើការជួបប្រទះនៅក្នុងប្រទេសថៃនិងតំបន់ព្រំដែនកម្ពុជា-ថៃ ខែ តុលា ឆ្នាំ ២០០៣ | |
|---|---|
| បញ្ហាដែលអ្នកចេញទៅធ្វើការជួបប្រទះ | |
| ត្រូវប៉ូលិសចាប់ | ២៣ |
| មិនបានទទួលបានលុយគ្រប់ចំនួន | ១១ |

| | |
|---|---|
| ត្រូវបានគេវាយដំ | ៧ |
| ធ្វើការលើសកំលាំងហើយឈឺ | ៤ |
| ត្រូវបានគេមើលងាយ | ៣ |
| កើតជំងឺគ្រុនចាញ់ | ២ |
| អត់មានបញ្ហា | ២២ |
| n = 61 | |

ដំណោះស្រាយសំខាន់នៅពេលគេចាប់ខ្លួន គឺបង់លុយអោយប៉ូលីស ។ ដំណោះស្រាយចំពោះបញ្ហាផ្សេងទៀតរួមមានឈប់ធ្វើការ ត្រឡប់មកផ្ទះ ខ្ចីលុយគេដើម្បីយកទៅមើលជំងឺ ។ អ្នកខ្លះនិយាយថាគេទ្រាំដោយខ្លាចបាត់បង់ការងារ ។ នៅពេលមានបញ្ហាពួកគេ ខិតខំដោះស្រាយដោយខ្លួនឯង ដោយពុំមានការជួយជ្រុំជ្រែងពីស្ថាប័ន និងអង្គការណាឡើយ ។

នៅក្នុងការសិក្សានេះ គេក៏បានសួរផងដែរចំពោះអ្នកដែលបានវិលត្រឡប់មកវិញពីបញ្ហាដែលគេបានជួបប្រទះនៅពេលដែលគេមកដល់ផ្ទះ (តារាងទី ៦) ។ តាមការប្រាប់របស់គេមាន ៤១% និយាយថាក្រោយត្រឡប់មកវិញ គេរកការងារធ្វើមិនបាន ៣០%និយាយថាគេត្រូវចាយលុយ ច្រើនលើការ មើលជំងឺហើយ ១៥%និយាយថាគេខ្សោយកំលាំងហើយមិន អាចធ្វើការធ្ងន់បាន ។ គួរកត់ចំណាំថា មាន ៣០%បាននិយាយថាគេមិនមានបញ្ហាទេនៅពេលត្រឡប់មកដល់ផ្ទះវិញ ។

| **តារាងតី ៦. បបញ្ហាដែលគេបានជួបប្រទះនៅពេលគេត្រឡប់មកដល់ផ្ទះវិញ តុលា ឆ្នាំ ២០០៣** | |
|---|---|
| **បញ្ហាដែលជួបប្រទះនៅផ្ទះ** | |
| រកការធ្វើមិនបាន | ២៥ |
| ត្រូវមើលជំងឺអស់លុយច្រើន | ១៨ |
| ខ្សោយកំលាំង ហើយធ្វើការងារធ្ងន់មិនបាន | ៩ |
| ជីវភាពធ្លាក់ចុះ | ៥ |
| ប៉ូលីសថៃនិងប៉ូលីសខ្មែរទារលុយ | ៣ |
| ត្រូវសងបំណុលគេ | ២ |

| | |
|---|---|
| អត់បញ្ហា | ១៨ |
| n = 61 | |

ជាទូទៅ អ្នកដែលបានត្រឡប់មកផ្ទះវិញមិនអាចដោះស្រាយបញ្ហាដែលគេជួបប្រទះនៅឯផ្ទះបានទេ ។ ភាគច្រើនទៅរកស៊ីឈ្នួលគេរយៈពេលខ្លី ប្រមូលស្បៀង ពឹងពាក់លើបងប្អូន ខ្ចីលុយគេ ពឹងលើលុយសន្សំ ហើយគ្រោងចេញទៅធ្វើការឆ្ងាយម្តងទៀត ។

ដូចគ្នានេះដែរ នៅពេលគេសួរទៅគ្រួសារដែលមានសមាជិកដែលបានចាកចេញបាត់ទៅមិនទាន់ត្រឡប់មកវិញ អំពីបញ្ហាដែលគេជួបប្រទះ នៅពេលដែលអ្នកនោះមិននៅ (តារាងទី ៧) ។ គ្រួសារជាច្រើនឆ្លើយថា គេមិនមានលុយគ្រប់គ្រាន់យកទៅទិញស្បៀង (សាច់ ត្រី បន្លែ) (៥៩%) ទិញអង្ករ (៤៦%) បញ្ជូនកូនទៅរៀន (២៧%) ហើយនិងទិញសំលៀកបំពាក់ (១៩%)។ ដូចគ្នានេះដែរ គេបានត្អូញត្អែរថាមិនមានមនុស្សគ្រប់គ្រាន់ ដើម្បីធ្វើស្រែ (២៤%) មើលថែទាំកូន (១៧%) ហើយនិងធ្វើការនៅក្នុងផ្ទះ (៣%) ។ ចំណាំៈ មាន២១% និយាយថា គេ មិនមានបញ្ហាទេនៅពេលដែលអ្នកចេញទៅមិនទាន់ត្រឡប់វិញ ។

| **តារាងទី៧. បញ្ហាដែលគ្រួសារបានជួបប្រទះ នៅពេលដែលអ្នកចាកចេញទៅមិនទាន់ត្រឡប់វិញ ខែតុលា ឆ្នាំ ២០០៣** | |
|---|---|
| **បញ្ហាដែលបានជួបប្រទះនៅពេលអ្នកចេញទៅមិនទាន់មកវិញ** | |
| ខ្វះលុយទិញស្បៀង (ក្រៅពីអង្ករ) | ៣៤ |
| ខ្វះលុយទិញអង្ករ | ២៧ |
| ខ្វះលុយដើម្បីបញ្ជូនកូនទៅរៀន | ១៦ |
| ខ្វះកំលាំងធ្វើស្រែ | ១៤ |
| ខ្វះលុយទិញសំលៀកបំពាក់ | ១១ |
| ខ្វះអ្នកមើលក្មេង | ១០ |
| ខ្វល់ពីកូនគ្រប់ពេលវេលា | ៣ |
| ខ្វះអ្នកធ្វើការនៅក្នុងផ្ទះ | ២ |

| | |
|---|---|
| ឈឺដោយសារធ្វើការលើសកំលាំង | ២ |
| ខ្វះអ្នកមើលគោ | ១ |
| គ្មានបញ្ហា | ១២ |
| n = 58 | |

ក្នុងចំណោមដំណោះស្រាយ សំរាប់បញ្ហាទាំងនេះ គេបាននិយាយថាគេបានដើរខ្ចីលុយ ស្រូវ ដើរបេះបន្លែ នេសាទ ជួញដូរនាយអាយ សុំបងប្អូនហូប សុំអោយបងប្អូនជួយមើលកូនតូចៗ និងអោយកូនធំជួយការងារបន្ថែម ពោលគឺពួកគេមិនបានទទួលការជួយឧបថម្ភអ្វីពីអង្គការណាទេ ។

## ជីវភាពរស់នៅ

តាំងតែពីប្រជាជនចាប់ផ្តើមចេញទៅធ្វើការងារឆ្ងាយពីផ្ទះមកធ្វើឱ្យមានការប្រែប្រួលនូវយុទ្ធសាស្ត្រក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់គេ ។ ពីមុនគ្រួសារទាំងនោះប្រកបរបរចំបងដូចជា ធ្វើស្រែ ដើរស៊ីឈ្នួលធ្វើស្រែចំការ ជួញដូរតូចតាច និង នេសាទ។ ក្រោយពីមានការចាកចេញទៅធ្វើការក្រៅមក ការងារធ្វើស្រែចំការ និងការស៊ីឈ្នួលតាមស្រែចំការ មានការថយចុះ ផ្ទុយទៅវិញការរកស៊ីជួញដូរតូចតាច និងនេសាទត្រី មានការកើនឡើង ។ ចំណែកឥឡូវនេះ ការចេញទៅធ្វើការ ក្រៅបានក្លាយទៅជាយុទ្ធសាស្ត្រចំបងនៅក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅសំរាប់គ្រួសារ។ បើពិនិត្យមើលជាទូទៅ ផលប្រយោជន៍ដែលបានមកពីការចាកចេញទៅធ្វើការងារខាងក្រៅនេះពុំបានជួយដល់ការធ្វើឱ្យជីវិភាពគ្រួសាររបស់ពួកគេរីកចំរើនទេ ពោលគឺវាគ្រាន់តែអាចជួយដោះទាល់រយៈពេលខ្លី និងសំរាប់ដោះបំណុលគេតែប៉ុណ្ណោះ ។

បើគិតអំពីបញ្ហា និងផលប្រយោជន៍ពីការចាកចេញទៅធ្វើពលកម្មនេះ តាមចំលើយអ្នកដែលបានសំភាសន៍ អ្នកខ្លះបានឆ្លើយថា អវិជ្ជមាន និងអ្នកខ្លះឆ្លើយថាវិជ្ជមាន (តារាងទី៨) ។ គេបាននិយាយថាស្ថានភាពគឺប្រសើរជាងមុន (២២%) គ្រួសារអាចទិញអង្ករ (១៣%) អាចទ្រទ្រង់ ខ្លួន ឯងបានមួយរយៈ (៦%) ហើយអាចសងបំណុលគេបាន (២%) ។ ចំណែកអ្នកដែលឆ្លើយថា អវិជ្ជមានវិញ បានបញ្ជាក់ថាស្ថានភាពគ្មានការប្រែប្រួលទេ(៤0%) ។ មានអ្នកខ្លះនិយាយថាស្ថានភាពកាន់តែយ៉ាប់យ៉ឺនទៅៗ

(១៦%) ។ ទោះបីជាយ៉ាងនេះក្តី នៅពេលដែលសួរថា តើអ្នកមានគម្រោងទៅទៀតឬទេ? ៦៤% ឆ្លើយថា គេនឹងទៅម្តងទៀត ។

| តារាងទី ៨. ផលប្រយោជន៍ពីការចាកចេញទៅធ្វើការខាងក្រៅ ចំពោះគ្រួសារ តុលា ២០០៣ | |
|---|---|
| ការពិពណ៌នា | |
| ស្ថានភាពនៅដដែល | ៤៨ |
| ស្ថានភាពបានគ្រាន់បើជាងមុនបន្តិច | ២៦ |
| ស្ថានភាពកាន់តែយ៉ាប់ជាងមុន( ជំពាក់គេកាន់តែច្រើន ក្រកាន់តែខ្លាំង) | ១៩ |
| គ្រួសារអាចទិញអង្ករបាន | ១៦ |
| គ្រួសារអាចទ្រទ្រង់ខ្លួនឯងបានមួយរយៈ | ៧ |
| គ្រួសារអាចសងបំណុលគេបាន | ២ |
| អត់ដឹង | ១ |
| n = 119 | |

## សេចក្តីសន្និដ្ឋាន

ទោះបីជាការធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃ ត្រូវបានគេទទួលស្គាល់ថាជានិន្នាការមួយយ៉ាងសំខាន់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះក្តី តែការនាំគ្នាទៅឈូឆរបែបនេះនៅក្នុងភូមិដែលយើងបានស្រាវជ្រាវនោះ គឺពិតជាធ្វើអោយគេមានការភ្ញាក់ផ្អើលមែនទែន។ មានចំនួនភាគរយខ្ពស់នៃគ្រួសារដែលធ្វើចំណាកស្រុកដើម្បីទៅធ្វើការក្រៅ ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺ ការចាកចេញទៅយ៉ាងគំហ៊ុកក្នុងរយៈពេល ពីរ-បីឆ្នាំកន្លងមកនេះ ។ ទោះបីជាមានព្រឹត្តិការណ៍ខ្លះៗ ដូចជា បាតុកម្មប្រឆាំងថៃនៅទីក្រុងភ្នំពេញនៅដើមឆ្នាំ ២០០៣ ក៏ដោយ ក៏ព្រឹត្តិការណ៍នេះ មិនបានកាត់ផ្តាច់ចលនាហូរចូលនៃកម្មករខ្មែរទៅក្នុងប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃទេ ។

ការសិក្សាបានរកឃើញថា ចំនួនអ្នកដែលចាកចេញទៅហើយចូលជ្រៅក្នុងប្រទេសថៃ មានចំនួនប្រហាក់ប្រហែលនិងអ្នកដែលចាកចេញទៅជិតៗតាមព្រំដែន ។ ចំពោះរយៈពេលនៃការធ្វើដំណើររបស់គេវិញគឺភាគច្រើនពី មួយខែទៅ៦ខែ ។ អ្នកចាកចេញទៅធ្វើការងារទាំងនោះមានប្រុស និងស្រីប្រហាក់ប្រហែលគ្នា ពួកគេភាគច្រើនមានអាយុពី ១៨ ទៅ៤៥ ឆ្នាំ ហើយសុទ្ធតែបានរៀបការរួច ។ ចំពោះចំណេះដឹងទូទៅវិញភាគច្រើន ពួកគេរៀនសូត្របានត្រឹមថ្នាក់ទី១ ដល់ថ្នាក់ទី៦ ប៉ុណ្ណោះ ។ លើសពីនេះទៀតពួកគេគ្មានដីធ្លីផងដែរ ។

ជាការពិតហើយថា តំលៃការងារខ្ពស់ និងឱកាសការងារមាននៅក្នុងប្រទេសថៃ ជាកត្តា "ទាញ" យ៉ាងសំខាន់ក៏ដោយ តែកត្តា "ជំរុញ" ពីប្រទេសកម្ពុជាក៏មានតួនាទីសំខាន់ផងដែរ ។ គ្រោះទឹកជំនន់ជាប់ៗគ្នានៅក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ បានជះឥទ្ធិពលធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះ ជំពាក់បំណុលដោយសារការធ្វើស្រែ គ្មានដីធ្លី ។ ដោយរួមផ្សំ និងការគ្មានការងារធ្វើនៅក្នុងតំបន់ក្បែរខាងផង ការធ្វើស្រែទៅមិនរួចបណ្តាលអោយគេស្វែងរកការងារនៅកន្លែងផ្សេង ។ ហើយអ្នកដែលបានលក់ស្រែ មិនអាចត្រឡប់មកប្រកបមុខរបរដូចដើមវិញបានឡើយ ។ ដោយសារតម្រូវការនៃសេដ្ឋកិច្ចទីផ្សារសេរី ប្រជាជនកម្ពុជាដែលពេញកំលាំង អាចចេញចូលទៅធ្វើការនៅកន្លែងផ្សេងបានដោយចំហរព្រំដែនរវាងកម្ពុជា-ថៃ បានកម្មករខ្មែរហូរចូលទៅក្នុងប្រទេសថៃ និងតំបន់ព្រំដែនជាបន្តបន្ទាប់ ។

ទាំងគ្រួសារ ទាំងអ្នកចាកចេញ ទទួលបានទាំងផលប្រយោជន៏ និងបញ្ហា ។ ចំពោះបញ្ហាដែលពួកគេជួបប្រទះវិញ តាមបទពិសោធន៏របស់ពួកគេ បានបញ្ជាក់ថា វាមិនមានភាពធ្ងន់ធ្ងរដូចដែលការសរសេរនៅក្នុងទំព័រកាសែតនោះទេ ។ ចំពោះបញ្ហាដែលពួកគេភាគច្រើនជួបប្រទះ គឺការចាប់ខ្លួន ។ ធ្ងន់ធ្ងរជាងនេះទៀតគេជួបប្រទះបញ្ហាធំៗនៅពេលត្រឡប់មកផ្ទះវិញ ។ គ្រួសារផ្សេងទៀតបានទទួលបន្ទុកបន្ថែមទៀត នៅពេលដែលអវត្តមាននូវសមាជិកគ្រួសាររបស់ពួកគេ ។ តែនៅក្នុងបរិបទនៃលក្ខខ័ណ្ឌដែលគេប្រឈមនោះ ហើយនិងឱកាសដែលមានសំរាប់គេ ការចេញទៅធ្វើការក្រៅនៅតែជាយុទ្ធសាស្ត្រសមស្រប ក្នុងការចិញ្ចឹមជីវិតគ្រួសាររបស់ពួកគេ ។

ពួកគេជាច្រើនបានយល់ឃើញថា ការចាកចេញនេះ វាគ្រាន់តែជួយដោះទាល់ប៉ុណ្ណោះ គេបានពោលថា ជីវភាពរបស់ពួកគេនៅដដែលមិនមានការប្រែប្រួលអ្វីទេ ។ អ្នកខ្លះនិយាយថា ជីវភាពរបស់ពួកគេគឺកាន់

តែយ៉ាប់យឺនទៅៗ ។ និយាយរួមអ្នកចាកចេញទៅធ្វើការនៅក្រៅមិនអាចយកប្រាក់ដែលខ្លួនរកបានទៅរកស៊ីអ្វីដើម្បីលើកកំពស់ជីវភាពគ្រួសាររបស់គេឡើយ ក្រៅពីប្រើប្រាស់សំរាប់ដោះទាល់ និងសងបំណុលគេនោះ ។

## អនុសាសន៍

នៅក្នុងឆ្នាំ ១៩៩៩ ការសិក្សារបស់វិទ្យាស្ថាន CDRI បានជួយផ្តល់ជាពតិមានដល់អ្នកអភិវឌ្ឍន៍សហគមន៍ និងរដ្ឋាភិបាល ចំពោះបញ្ហានៃការធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ។ ទោះជាធ្វើយ៉ាងនេះក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាលមិនបានធ្វើអ្វីដើម្បីឆ្លើយតបទៅនឹងបញ្ហានេះនៅឡើយទេ ។ ជាទូទៅ អង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នរដ្ឋពេញចិត្តនឹងអនុវត្តកម្មវិធីរបស់គេដោយមិនគិតគូរឱ្យបានគ្រប់គ្រាន់ដល់ការប្រែប្រួល ខុសពីប្រក្រតីនៃយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតដែលកំពុងតែកើតមានឡើងនៅចំពោះមុខគេ ។ ដូច្នោះ នេះជាឱកាសសំរាប់អង្គការនានាដែលកំពុងធ្វើការខាងផ្នែកអភិវឌ្ឍន៍សហគមន៍ក្តី ច្បាប់ក្តី និងសិទ្ធិមនុស្សក្តី ក្នុងការរួមគ្នាដោះស្រាយចំពោះបញ្ហានេះ ។ វាក៏ជាឱកាសល្អសំរាប់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការចំពោះបញ្ហានេះ ដោយធ្វើការសហប្រត្តិបត្តិការជាទ្វេភាគីជាមួយនឹងប្រទេសថៃ ដើម្បីការពារ និងជួយដល់កម្មករកម្ពុជា ។

<u>ខាងក្រោមនេះជាអនុសាសន៍ និងចំណោទដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវគិតគូរ:</u>

- អង្គការមិនមែនរដ្ឋាភិបាលគួរគិតសារជាថ្មីឡើងវិញ អំពីកម្មវិធីអភិវឌ្ឍន៍សហគមន៍របស់គេ ដើម្បីជាយុទ្ធសាស្ត្រសំរាប់ភូមិ ដែលការចាកចេញទៅធ្វើការងារនេះកំពុងរីករាលដាល ។
- អង្គការមិនមែនរដ្ឋាភិបាលគួរពិនិត្យមើលមធ្យោបាយផ្សេងៗដែលអាចកាត់បន្ថយល័ក្ខខ័ណ្ឌនានាដែលបណ្តាលឱ្យអ្នកភូមិចាកចេញទៅប្រកបការងារខាងក្រៅ ។ ល័ក្ខខ័ណ្ឌទាំងនេះរួមមានការបំប៉នចំណេះដឹង អំពីការគ្រប់គ្រងបញ្ហាធននាធម្មជាតិ ជាពិសេសបញ្ហាដែលទាក់ទងទឹកជំនន់ និងបញ្ហាគ្មានដីធ្លី ។
- អង្គការមិនមែនរដ្ឋាភិបាលត្រូវតែរកមធ្យោបាយធ្វើយ៉ាងណាដើម្បីអាចផ្តល់ជំនួយដោយផ្ទាល់ដល់អ្នកចាកចេញ និងគ្រួសាររបស់គេ ។ ជំនួយទាំងអស់នោះ រាប់បញ្ចូលទាំងការអប់រំច្បាប់ និង

សិទ្ធមនុស្ស ព្រមទាំងផ្តល់សេវាសុខភាពដល់អ្នកដែលត្រឡប់មកវិញ ។ ប្រហែលជាការល្អ បើសិនជាអ្នកចាកចេញអាចចងក្រងជាក្រុមជួយគ្នាទៅវិញទៅមកនៅក្នុងភូមិនីមួយៗ ។

- ❖ អង្គការមិនមែនរដ្ឋាភិបាលគួរតែបង្កើតការសហប្រតិបត្តិការជាមួយ អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងប្រទេសថៃ ដើម្បីសំរបសំរួល និងជួយដល់កម្មករខ្មែរដែលធ្វើការនៅក្នុងប្រទេសថៃ ។
- ❖ អង្គការមិនមែនរដ្ឋាភិបាលគួរតែធ្វើការតស៊ូមតិជាមួយរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាអោយសិទ្ធិមនុស្ស និងសិទ្ធិស្របច្បាប់របស់កម្មករ ដែលចេញទៅធ្វើការទាំងនោះត្រូវបានគេគោរពឱ្យបានទូលំទូលាយ ។

<u>ខាងក្រោមនេះជាអនុសាសន៍ និងចំណោទដែលភ្នាក់ងាររាជរដ្ឋាភិបាលត្រូវគិតគូរៈ</u>

- ❖ រាជរដ្ឋាភិបាលកម្ពុជាគួរតែចូលរួមពិភាក្សាជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីធានាភាពស្របច្បាប់ចំពោះកម្មករខ្មែរដែលបានចូលទៅធ្វើការនៅប្រទេសថៃ ។ ចំណុចដែលត្រូវពិភាក្សារួមមានសិទ្ធិមនុស្ស និងសិទ្ធិច្បាប់ ដោយបង្កើតទីស្នាក់ការរបស់រដ្ឋាភិបាលខ្មែរ នៅក្នុងប្រទេសថៃ ដើម្បីជួយដោះស្រាយបញ្ហាដែលទាក់ទងនឹងការងាររបស់កម្មករនៅក្នុងប្រទេសថៃ ។ ក្នុងនោះដែររដ្ឋាភិបាលត្រូវមានគោលការណ៍ច្បាស់លាស់ក្នុងការត្រួតពិនិត្យការងាររបស់មេខ្យល់ និងភ្នាក់ងារជ្រើសរើសកម្មករទៅធ្វើការនៅប្រទេសក្រៅ ។ វាជាការប្រសើរក្នុងការពង្រឹងទំនាក់ទំនងរវាងខេត្តដែលមានព្រំប្រទល់ជាប់គ្នា រវាងកម្ពុជា-ថៃ ជាពិសេសមន្ត្រីរាជការ និងប៉ូលីសនៅតាមព្រំដែននៃប្រទេសទាំងពីរ ។
- ❖ ស្ថាប័នរដ្ឋាភិបាល គួរតែកំណត់ឱ្យបានច្បាស់លាស់ នូវតួនាទីទទួលខុសត្រូវរបស់ពួកគេ ចំពោះបញ្ហាការចាកចេញទៅធ្វើការនៅក្រៅប្រទេស ។
- ❖ ស្ថាប័នរដ្ឋាភិបាល គួរតែពង្រឹងការងារកសិកម្ម អភិវឌ្ឍន៍ជនបទ និងការគ្រប់គ្រងធនធានធម្មជាតិដើម្បីកាត់បន្ថយនូវល័ក្ខខ័ណ្ឌនានា ដែលជំរុញឱ្យប្រជាជនចាញចេញពីភូមិរបស់គេ ។
- ❖ ស្ថាប័នរដ្ឋាភិបាល គួរតែផ្តល់វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ ក្រៅពីការងារធ្វើស្រែ ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ ។

**ឧបសម្ព័ន្ធ**

## ផែនទីភូមិស្រាវជ្រាវក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង




៤

## ១. សំណួរសម្រាប់សំភាសន៍អ្នកចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ

ប្រវត្តិរបស់សមាជិកគ្រួសារអ្នកចេញទៅប្រកបការងារដែលត្រូវបានសំភាសន៍

១- ឈ្មោះភូមិ
- ☐ គោកក្តួច
- ☐ អង់
- ☐ ទំពូង
- ☐ ប៉ោយយ៉ុង

២- ភេទ ☐ ប្រុស ☐ ស្រី

៣- អាយុ
- ☐ ក្រោម ១៨ ឆ្នាំ
- ☐ ១៨-៣០ ឆ្នាំ
- ☐ ៣១- ៤៥ ឆ្នាំ
- ☐ ៤៦- ៦០ ឆ្នាំ
- ☐ ច្រើនជាង ៦០ ឆ្នាំ

៤- ស្ថានភាពគ្រួសារ
- ☐ លីវ
- ☐ មានគ្រួសារ
- ☐ ម៉េម៉ាយ/ពោះម៉ាយ

៥- ចំនួនកូនក្នុងបន្ទុក:.................................................................

៦- ចំនួនសមាជិកគ្រួសារ ( រាប់ទាំងអ្នកចេញទៅប្រកបការងារ ):.............................................

៧- តើមានសមាជិកគ្រួសារប៉ុន្មាននាក់ដែលអាចរកចំណូលជាលុយ និងសំភារៈផ្សេងៗ ដើម្បីទ្រទ្រង់គ្រួសារ?

....................................................................................................................................

៨- ការអប់រំ: ( បំពេញកម្រិតវប្បធម៌ដែលគេបានរៀន)
- ☐ មិនបានចូលសាលារៀន
- ☐ ថ្នាក់ទី ១-៦

☐ថ្នាក់ទី៧-៩

☐ថ្នាក់ទី ១០-១២

☐ចូលមហាវិទ្យាល័យ

**ដីកម្មសិទ្ធិ និងការបង្កបង្កើនផល**

៩- តើគ្រួសាររបស់អ្នកមានដីស្រែ ឬទេ? ☐មាន

☐មិនមាន

១០- តើគ្រួសាររបស់អ្នកមានដីធ្វើស្រែប៉ុន្មានហិកតា?

☐0,៥ហិកតា ឬតិចជាង

☐0,៥១-១ ហត

☐១,១-២ ហត

☐២,១-៣ ហត

☐លើសពី៣ ហត

☐N/A

១១- តើគ្រួសាររបស់អ្នកជួលដីស្រែគេ ឬទេ?

☐ជួល

☐មិនជួល

១២- តើគ្រួសាររបស់អ្នកជួលដីស្រែគេ ប៉ុន្មានហិកតា ?

☐0,៥ហិកតា ឬតិចជាង

☐0,៥១-១ ហត

☐១,១-២ ហត

☐២,១-៣ ហត

☐លើសពី៣ ហត

☐N/A

១៣- តើទិន្នផលស្រូវដែលអ្នកទទួលបានប្រចាំឆ្នាំ ជាទូទៅអាចផ្គត់ផ្គង់គ្រួសាររបស់អ្នកគ្រប់គ្រាន់ឬទេ ?

☐បាទ/ចាំ

☐ទេ

☐N/A

១៤-បើសិនជាមិនគ្រប់គ្រាន់ទេ តើខ្វះប៉ុន្មានខែ ?

☐ ១ ខែ

☐ ២ ខែ

☐ ៣ ខែ

☐ ៤ ខែ

☐ ៥ ខែ

☐ លើសពី ៥ ខែ

☐N/A

១៥- តើគ្រួសាររបស់អ្នកធ្វើស្រែ ឬទេនៅឆ្នាំនេះ ?

☐បាទ/ចាំ

☐ទេ

☐N/A

១៦- បើទេ តើហេតុអ្វី? (បំពេញហេតុផល): ........................................................................ .......

.........................................................................................................................................

☐N/A

១៧- តើគ្រួសាររបស់អ្នកធ្លាប់លក់ដីស្រែ ដែរឬទេ?

☐បាទ/ចាំ

☐ទេ

១៨- បើធ្លាប់លក់ តើគ្រួសាររបស់អ្នកលក់ប៉ុន្មានហិកតា ?

☐0,៥ហិកតា ឬតិចជាង

☐0,៥១-១ ហត

☐១,១-២ ហត

☐២,១-៣ ហត

☐លើសពី៣ ហត

☐N/A

១៩- បើធ្លាប់លក់ តើមកពីមូលហេតុអ្វី? (បំពេញហេតុផល):..........................................................

.......................................................................................................................................

☐N/A

**បទពិសោធន៍របស់អ្នកចេញទៅប្រកបការងារសំខាន់បំផុតនៅក្នុងគ្រួសារស**

